# បក្សជាប់ឆ្នោតទាំងពីរនៅតែខ្វែងគ្នាលើច្បាប់បោះឆ្នោត

Tue, 17 February 2015

មាស សុខជា ភ្នំពេញ ប៉ុស្តិ៍

ភ្នំពេញៈ គណបក្សកាន់អំណាចនិងគណបក្សប្រឆាំងនៅតែស្ថិតក្នុងភាពចម្រូងចម្រាសអំពីតួនាទីនៃមន្ត្រីតុលាការ និងកងប្រដាប់អាវុធនៅក្នុងដំណើរការនៃការបោះឆ្នោត ខណៈគណបក្សកាន់អំណាចទាមទារឲ្យមន្ត្រីទាំងពីរប្រភេទនេះចូលរួមដំណើរការបោះឆ្នោត ប៉ុន្តែ គណបក្សប្រឆាំងច្រានចោល។

បន្ទាប់ពីកិច្ចប្រជុំបីម៉ោងនៅក្នុងរដ្ឋសភា កាលម្សិលមិញ លោក គួយ ប៊ុនរឿន ប្រធានក្រុមការងារគណបក្សសង្គ្រោះជាតិបានប្រាប់អ្នកកាសែតថា ច្បាប់ស្តីពីគណបក្សនយោបាយមិនអនុញ្ញាតឲ្យមន្ត្រីតុលាការនិងកងប្រដាប់អាវុធចូលរួមយុទ្ធនាការនយោបាយទេ ព្រោះវាធ្វើឲ្យមន្ត្រីទាំងនោះបាត់បង់អព្យាក្រឹតភាពក្នុងការបម្រើជាតិ។

លោកថ្លែងថា គណបក្សប្រជាជនកម្ពុជា ទាមទារដូច្នេះវាធ្វើឲ្យតុលាការនិងកងប្រដាប់អាវុធ នគរបាល កងទ័ពលម្អៀងទៅរកគណបក្សនយោបាយ។

លោក គួយ ប៊ុនរឿន ថ្លែងបន្តថា៖ «គណបក្សប្រជាជនកម្ពុជា នៅតែលើកហេតុផលសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ។ ប៉ុន្តែគណបក្សសង្គ្រោះជាតិគិតថា វាប៉ះពាល់ដល់ច្បាប់ស្តីពីនយោបាយនៅមាត្រា ១៥ ដែលហាមរាល់សកម្មភាពនៃកងប្រដាប់អាវុធ មន្ត្រីតុលាការមិនឲ្យគាំទ្រឬប្រឆាំងបក្សនយោបាយណាមួយ»។

លោកបន្តថា៖ «កងប្រដាប់អាវុធគឺជាកម្លាំងប្រដាប់អាវុធរបស់ប្រទេសជាតិមិនមែនជារបស់គណបក្សនយោបាយទេ។ ដូច្នេះ បើពួកគេធ្វើសកម្មភាពគាំទ្រឬប្រឆាំង វាអាចនឹងប៉ះពាល់គោលការណ៍បោះឆ្នោត ហើយធ្វើឲ្យប្រជាជនភ័យខ្លាច»។

ទាក់ទិននឹងអង្គការសង្គមស៊ីវិលចូលរួមក្នុងដំណើរការបោះឆ្នោតលោក ប៊ុនរឿន ថ្លែងថា គណបក្សសង្គ្រោះជាតិទាមទារឲ្យគណបក្សប្រជាជនលុបច្បាប់ដែលហាមសង្គមស៊ីវិល មិនឲ្យរិះគន់ពីភាពមិនប្រក្រតីនៃការបោះឆ្នោតដោយហាមអង្គការទាំងនោះ មិនឲ្យធ្វើសេចក្តីថ្លែងការណ៍ណាមួយឬអត្ថាធិប្បាយលើស្ថានភាពនោះទេ។

លោក ប៊ិន ឈិន ប្រធានក្រុមការងាររបស់គណបក្សប្រជាជនថ្លែងតបថា មន្ត្រីតុលាការ នគរបាល និងកងទ័ពជាមនុស្សដែរ ដូច្នេះ ពួកគេអាចចូលរួមរាល់សកម្មភាពក្នុងការបោះឆ្នោត។

លោកបើកសៀវភៅច្បាប់ស្តីពីគណបក្សនយោបាយអានប្រាប់អ្នកកាសែតថា ច្បាប់ស្តីពីការបោះឆ្នោតចែងថា ព្រះសង្ឃ មន្ត្រីតុលាការ ទាហាន អាចចូលរួមជាសមាជិកគណបក្សនយោបាយ។

លោកថ្លែងថា៖ «នេះគឺដោយសារយើងចង់ឲ្យពួកគេមានសិទ្ធិគ្រប់គ្រាន់»។

លោក ប៊ិន ឈិន បន្តថា៖ «យើងគោរពច្បាប់នេះ។ យើងមិនរៀបចំរចនាសម្ព័ន្ធគណបក្សក្នុងអង្គភាពនគរបាល និងកងទ័ពទេ។ យើងបានសរសេរច្បាប់នេះថា បន្ទាប់ពីចប់ម៉ោងការងារឬក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលធ្វើការនៅក្នុងសមត្ថភាពផ្លូវការ អាជ្ញាធរ កងប្រដាប់អាវុធ នគរបាលជាតិ និងមន្ត្រីតុលាការអាចចូលរួមសកម្មភាពឃោសនាដើម្បីគាំទ្រគណបក្សនយោបាយឬបក្សណាមួយ»។

លោកបញ្ជាក់ថា សង្គមស៊ីវិលត្រូវតែមានជំហរអព្យាក្រឹតនៅពេលបំពេញតួនាទីក្នុងយុទ្ធនាការបោះឆ្នោតគឺដូចនៅក្នុងពេលបោះនិងរាប់សន្លឹកឆ្នោត។

លោកបន្តថា៖ «យើងគ្មានបំណងហាមពួកគេពីការបង្ហាញមតិយោបល់ទេ ប៉ុន្តែពេលពួកគេធ្វើសេចក្តីថ្លែងការណ៍គឺត្រូវតែនិយាយអំពីការពិត ក្នុងន័យអព្យាក្រឹតនិងឯករាជ្យ»។ លោកថា បើមិនផ្អែកលើការពិត ច្បាប់ចែងអំពីកំហុស ប៉ុន្តែលោកមិនលម្អិតអំពីកម្រិតទោសទណ្ឌទេ។

លោក គល់ បញ្ញា នាយកនៃអង្គការឃ្លាំមើលការបោះឆ្នោត គាំទ្រលោក គួយ ប៊ុនរឿន ថា៖ «យើងត្រូវតែហាមមន្ត្រីតុលាការ នគរបាល កងទ័ព ពីព្រោះពួកគេទទួលខុសត្រូវ ដូច គ.ជ.ប ក្នុងអំឡុងការបោះឆ្នោត។ បើយើងមិនអាចដោះស្រាយបញ្ហាបោះឆ្នោតបាន យើងនឹងបញ្ជូនទៅតុលាការ។ ច្បាប់ហាមរាល់សកម្មភាពទាំងអស់។ បើយើងមិនហាមនគរបាល កងទ័ព វានឹងជួបបញ្ហាខ្លាំង...។ បើធ្វើសកម្មភាពឲ្យគណបក្សណាមួយ ពួកគេនឹងគំរាមកំហែងគណបក្សណាមួយ»៕